# សុន្ទរកថា
# សន្និសីទស្តីពីច្បាប់អន្តរជាតិ និងសាសនាប្រចាំឆ្នាំ លើកទី ២២ “សន្និសីទស្តីពី សាសនា ច្បាប់ និងស្ថេរភាពសង្គម”

ប្រារព្ធធ្វើឡើងនៅថ្ងៃទី ៤-៧ ខែតុលា ឆ្នាំ២០១៥ នៅឯសាកលវិទ្យាល័យព្រីខាំ យ៉ាំង, ព្រូវ៉ូ, យូតា, សហរដ្ឋអាមេរិក..

*សូមគោរពគណៈអធិបតីជាទីគោរព!*
*សូមគោរពប្រមុខដឹកនាំសាសនាទាំងអស់ជាទីគោរព!*
*សូមគោរព អស់លោក លោកស្រីភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!*

ខ្ញុំមានកិត្តិយស និងសេចក្តីរំភើបរីករាយដោយបានចូលរួមជាមួយនឹងឯកឧត្តម អស់លោក លោកស្រី នៅក្នុងសន្និសីទនាឆ្នាំនេះស្តីអំពី **សាសនា ច្បាប់** និង**ស្ថេរភាពសង្គម**។

ជំនួសមុខឲ្យគណៈប្រតិភូ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសំដែងនូវការគោរពថ្លែងអំណរគុណដោយស្មោះចំពោះព្រះវិហារសាសនាចក្រនៃគ្រីស្ទបរិស័ទថ្ងៃចុងក្រោយ,ជាពិសេសចំពោះមជ្ឈមណ្ឌលសិក្សាច្បាប់ និងសាសនាអន្តរជាតិ, នៃសាកលវិទ្យាល័យ **ព្រីខាំ យ៉ាំង** ដែលបានអញ្ជើញយើងខ្ញុំ ចូលរួមក្នុងកិច្ចប្រជុំនេះ ដើម្បីបានចែករំលែកនូវគំនិតយោបល់ បទពិសោធន៍ និងព័ត៌មានផ្សេងៗ លើកកម្ពស់សេរីភាពជំនឿសាសនា ជាពិសេស ដើម្បីពង្រឹងនូវមូលដ្ឋានគ្រឹះនៃសេចក្តីសណ្តោសប្រណី និងការយោគយល់អធ្យាស្រ័យខាងសាសនា ក្នុងចំណោមវប្បធម៌ផ្សេងៗគ្នា។

កម្ពុជាមានមោទនភាពថា ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន កម្ពុជាពុំដែលមានប្រវត្តិនៃជម្លោះសាសនាឡើយ ហើយបន្ថែមលើនេះទៀត កម្ពុជាបានដើរតួនាទីជាមជ្ឈមណ្ឌលនៃការបង្រួបបង្រួមនៃអន្តរជំនឿជាច្រើនវេទិកា, ជាក់ស្តែង កិច្ចប្រជុំកាលពីថ្ងៃទី ៣-៦ ខែមេសា ឆ្នាំ២០០៨ នៅរាជធានីភ្នំពេញ ស្តីពីការសហប្រតិបត្តិការអន្តរជំនឿ ដើម្បីសន្តិភាព និងភាពសុខដុមនីយកម្ម រួមទាំងមានសិក្ខាសាលាជាច្រើនទៀត ជារួម កម្ពុជាជាប្រទេសប្រកាន់ភ្ជាប់នូវការផ្តល់សិទ្ធិសេរីភាពជំនឿសាសនា។ ទន្ទឹមនេះ រាជរដ្ឋាភិបាល ក៏បានយកចិត្តទុកដាក់ផ្តល់សេរីភាពយ៉ាងទូលំទូលាយ និងពេញលេញជូនដល់ប្រជាជនទូទៅ ក្នុងការគោរពប្រណិប័តន៍ខាងជំនឿសាសនាដទៃៗទៀត ដោយឈរលើមូលដ្ឋាននៃការពង្រឹងសុខដុមនីកម្មរវាងសាសនិកនៃគ្រប់និកាយសាសនា ប្រឆាំងរាល់ទង្វើនៃការរើសអើង ការបែងចែកក្នុងចំណោមប្រជាជន ដែលបណ្តាលមកពីភាពខុសគ្នានៃជំនឿសាសនា សំដៅទប់ស្កាត់ការយកសាសនាធ្វើជាអាជីវកម្ម

ដែលអាចបង្កជាវិបត្តិសាសនា ឲ្យទៅជាកំលាំងជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ព្រមទាំងពង្រឹងសន្តិភាព សាមគ្គីភាព ថែរក្សាព្រៃឈើជាតិ និងលើកកម្ពស់តម្លៃសីលធម៌សង្គមជាតិ។

ស្របជាមួយនឹងកំណើនសេដ្ឋកិច្ចមានការរីចចម្រើន, ការធ្វើហេដ្ឋារចនាសម្ព័ន្ធនានា, ស្ថេរភាពនយោបាយ និងសេរីភាពខាងការប្រតិបត្តិសាសនា គឺមានការជម្រុញលើកទឹកចិត្តយ៉ាងពេញទំហឹង។ សេរីភាពខាងការប្រតិបត្តិសាសនាគឺត្រូវបានយកចិត្តទុកដាក់ជាមួយនឹងការគោរពគ្នាទៅវិញទៅមក ក្នុងក្រនខ័ណ្ឌច្បាប់ជាមូលដ្ឋាន ដូចជា ព្រះពុទ្ធសាសនា គ្រីស្ទសាសនា ឥស្លាមសាសនា ។ល។ សេរីភាពខាងជំនឿសាសនា ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ត្រង់មាត្រា ៤៣ ដែលចែងថា " *ប្រជាជនទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និងការប្រតបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ឬដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ* ។

ក្រសួងឈ្វេងយល់ឃើញថា តាមរយៈការបដិបត្តិសាសនា, មាតាបិតាទាំងឡាយគឺមានលទ្ធភាពធ្វើជាគំរូដល់កូនចៅក្នុងគ្រួសារ ។ សាសនាបានផ្តលជាក្នុងសង្គមគ្រួសារ, ដែលនាំមកនូវស្ថេរភាព និងភាពសុខដុមរមនាដល់គ្រួសារ, ភូមិ ស្រុក ខេត្ត និងប្រទេសជាតិទាំងមូល។

លើមូលដ្ឋានគ្រឹះនៃការពង្រឹងសុខដុមនីយ៍ផ្នែកសាសនា,គឺត្រូវមានគោលការណ៍អនុវត្តដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល និងតួនាទីដ៏ត្រឹមត្រូវរបស់សាសនានីមួយៗក្នុងការលើកកំពស់ចំណេះដឹង គុណធម៌ សុជីវធម៌ ការគោរពប្រតិបត្តព្រះធម៌វិន័យ និងការចូលរួមចំណែកអភិវឌ្ឍសង្គមជាតិ។

ដើម្បីរក្សាសង្គមមួយប្រកបដោយសុខសន្តិភាពនិងវឌ្ឍនភាព គប្បីយកចិត្តទុកដាក់លើគោលការមួយចំនួនដូចខាងក្រោម៖

១.គោរពកិច្ចសហប្រតិបត្តិការ សាមគ្គីភាពយ៉ាជិតស្និទ្ធ ស្មោះត្រង់ ដោយឈរលើគោលការគោរពគ្នា អធ្យាស្រ័យគ្នា យោគយល់គ្នា គ្រប់កាលៈទេសៈទាំងអស់ ដើម្បីសាមគ្គីភាព និងសុខដុមរមនានៃសង្គមនជាតិ។

២ .យើងគប្បីលើកទឹកចិត្តផ្តល់ជាវិភាគទាននិងសិក្សាវិធីវិទ្យាសាស្រ្តពិភពលោកហើយនឹងឈ្វេងយល់នូវភាពសុខប្លែកគ្នាក្នុងចំណោមសាសនា, វិទ្យាសាស្រ្ត និងជាតិនានា, ដើម្បីបញ្ជៀសនូវរាល់ការជ្រុលនិយមនៅក្នុងគំនិត និងជំនឿរបស់ខ្លួន ហើយបដិបត្តិនូវចរិយា ធម៌ និងទំនួសខុសត្រូវនៃសេចក្តីសណ្តោស និងការយកយល់គ្នានៃសាសនានានា និងបញ្ហា អន្តរ

វប្បធម៌សម្រាប់ជាលាភការ។

៣.គោរពសិទ្ធិសេរីភាពជំនឿសាសនារបស់បុគ្គលជាតម្លៃនៃជំនឿសាសនានីមួយៗក្នុងការវិភាគឈ្វេងយល់ផ្លូវត្រូវសម្រាប់សុភង្គលរបស់សង្គមជាតិ។

៤.យើងត្រូវពង្រឹងការអប់រំ គប្បីធ្វើឲ្យមានភាពរីកចម្រើនឡើងនូវបញ្ញត្តិអប់រំ និងគោលការគ្រឹះនៃពហុវប្បធម៌ និងប្រពៃណីសម្រាប់មនុស្សរាល់គ្នា ជាពិសេសចំពោះយុវជន និងស្ត្រីទាំងឡាយដែលជាអ្នកពិតជាត្រូវការការណែនាំ និងការរៀបចំសមស្របត្រឹមត្រូវ។

សរុបសេចក្តីមក សេរីភាពខាងជំនឿសាសនាគឺមានអត្ថន័យលុះត្រាណាតែមានសន្តិភាព និងភាពសុខដុមរមនា ដោយផ្អែកលើការចេះយោគយល់ អធ្យាស្រ័យគ្នា ស្មោះត្រង់ប្រព្រឹត្តតែអំពើល្អ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា នឹងមានការផ្លាស់ប្តូរ ចែករំលែកនូវគំនិត ចំណេះដឹង បទពិសោធន៍ និងចក្ខុវិស័យនៅក្នុងអង្គសន្និសីទនេះ ដើម្បីរួមចំណែកសំខាន់ ស្តីពីបញ្ហាសាសនា ច្បាប់ និងសន្តិសុខសង្គម ដែលនាំឲ្យសម្រេចបានវប្បធម៌សន្តិភាពគ្រប់ជំនឿសាសនាទាំងអស់លើសាកលលោក។ សូមឲ្យសន្តិភាព ភាពសុខដុមរមនា និងសេរីភាពខាងជំនឿសាសនាមានលើពិភពលោកដោយសារអង្គសន្និសីទនេះ៕

*សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់អស់លោកអ្នក!*